រាជរដ្ឋាភិបាលកម្ពុជា

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

របាយការណ៍វឌ្ឍនភាព

យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ

ងី ចន្ទ្រផល

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធាន ក.ក.ជ.

កិច្ចប្រជុំលើកទី១៧ នៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍

ថ្ងៃចន្ទ ទី១៨ ខែតុលា ឆ្នាំ២០១០ — នៅវិមានរដ្ឋាភិបាល (ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)

សូមគោរព ឯកឧត្តមប្រធានអង្គប្រជុំ

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ

អង្គប្រជុំទាំងមូល ជាទីគោរពរាប់អាន

**១.** ជាបឋម ក្នុងនាម ឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ខ្ញុំមានកិត្តិយសធ្វើការបង្ហាញដោយសង្ខេបពីដំណើរការវឌ្ឍនភាពនៃការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រគាំពារសង្គមនៅកម្ពុជា បន្ទាប់ពីបានបង្ហាញសេចក្តីព្រាងជាលើកដំបូងនៅក្នុងសម័យប្រជុំវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា លើកទី៣ នាខែមិថុនា ២០១០កន្លងមកនេះ ។ ឆ្លៀតយកឱកាសនេះខ្ញុំសូមអនុញ្ញាតិដើម្បីសំដែងនូវគារវកិច្ចអំណរគុណ ចំពោះឯកឧត្តម លោកជំទាវ ជាតំណាងក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ព្រមទាំងបណ្តាអង្គការសង្គមស៊ីវិល ដែលបានគាំទ្រ ចូលរួម និងធ្វើការ វិភាគទានប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីរៀបចំចងក្រងនូវសេចក្តីព្រាង យុទ្ធសាស្ត្រនេះ ដែលបានដំណើរការអស់ពេល១៨ខែ ។

**២.** របៀបវារៈនៃការចងក្រង **យុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនក្រីក្រនិងងាយរងគ្រោះ** គឺបានរៀបចំឡើងនៅក្នុងក្របខណ្ឌនៃការធ្វើសម្រេចបាន នូវគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នេះបានកំណត់ជាយុទ្ធសាស្ត្រលើកកំពស់ការពង្រីកកិច្ចគាំពារសង្គមសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ និងចង្អុលទិស ដើម្បីរៀបចំឱ្យមាននិងអនុវត្តនូវយុទ្ធសាស្ត្រគាំពារសង្គម និងប្រព័ន្ធសុវត្ថិភាពសង្គម ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ស៊ីសង្វាក់ បំពេញបន្ថែមគ្នាទៅវិញទៅមក និងមាននិរន្តរភាព ។ របាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ខែកញ្ញា ឆ្នាំ២០១០ ក៏មានចែងរំលេចអំពីសារសំខាន់ជាយុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាលក្នុងកិច្ចការគាំពារសង្គម ដើម្បីកាត់បន្ថយភាពក្រីក្រ និងងាយរងគ្រោះ ដោយបញ្ជាក់ពីការចាំបាច់ពង្រីកវិសាលភាពនៃកិច្ចគាំពារសង្គម និង បណ្តាញសុវត្ថិភាពសង្គម ឱ្យបានទូលំទូលាយ សម្រាប់ជា

សំណាញ់ការពារជនងាយរងគ្រោះនិងជនក្រីក្រ មិនឱ្យធ្លាក់នៅក្នុងគ្រោះហានិភ័យ ដែលកើតឡើងដោយសារវិបត្តិសេដ្ឋកិច្ចជាដើម និងជំរុញប្រើប្រាស់វិធានការជាក់ស្តែង ដើម្បីជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ។

៣. ដើម្បីជាជំនួយស្មារតីនៃកិច្ចប្រជុំនេះ ខ្ញុំសូមរៀបរាប់ជាសង្ខេបពីសារបាននៃការរៀបចំយុទ្ធសាស្រ្តនេះត្រួស១ ដូចតទៅនេះ។ នៅក្នុងកិច្ចប្រជុំវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២ កាលពីថ្ងៃទី៣-៤ ខែធ្នូ ឆ្នាំ២០០៨ នៅទីក្រុងភ្នំពេញ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍បានធ្វើការកត់សម្គាល់ឃើញនូវវឌ្ឍនភាព ជាច្រើន ដែលត្រូវបានសម្រេចឡើងនាពេលកន្លងមក ពិសេសក្នុងការកាត់បន្ថយភាពក្រីក្រ ប៉ុន្តែស្របពេលជាមួយគ្នា ក៏បានទទួលស្គាល់ថា ផ្នែកខ្លះនៃប្រជាជនកំពុងស្ថិតនៅក្នុងស្ថានភាព ដែលងាយនឹងទទួលរងគ្រោះពីវិបត្តិ សង្គម និងសេដ្ឋកិច្ចមួយចំនួន ដែលអាចរុញច្រានពួកគេឱ្យធ្លាក់ទៅក្នុងភាពក្រីក្រ។ ជំហានដំបូងនៃការងារនេះ គឺការរៀបចំឡើងនូវកិច្ចការវិភាគទូទៅ ក្នុងការកំណត់នូវវិសាលភាព នៃប្រព័ន្ធសុវត្ថិភាពសង្គមដែលមានស្រាប់ និងការកំណត់ទិសដៅគោលនយោបាយ ព្រមទាំងជំរើសយុទ្ធសាស្រ្តសម្រាប់ការបង្កើតឡើងនូវប្រព័ន្ធសុវត្ថិភាព សង្គមមួយ ដែលមានលក្ខណៈចម្រុះនិងជាប្រព័ន្ធ និងស្របតាមស្ថានភាពសង្គម-សេដ្ឋកិច្ចនៅកម្ពុជា។

៤. ខ្លឹមសារនៃសេចក្តីព្រាងយុទ្ធសាស្រ្តនេះក៏បានធ្វើការបង្ហាញជូនដល់អង្គ **វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣** កាលពីថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១០ រួចហើយដោយបានទទួលការគាំទ្រពីសំណាក់ថ្នាក់ដឹកនាំក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលផងដែរ។ ទស្សនទាន ចក្ខុវិស័យជាក្របខណ្ឌនៃយុទ្ធសាស្រ្តគាំពារសង្គមសម្រាប់ក្រុមជនក្រីក្រ និងជនងាយរងគ្រោះ បានត្រូវរៀបចំតាក់តែងឡើង ដោយមានការថ្លឹងថ្លែង រវាងដំណោះស្រាយដើម្បីការកាត់បន្ថយភាពក្រីក្ររាំរ៉ៃផង ជួយជនក្រីក្រឱ្យមានសមត្ថភាពឆ្លើយតបនូវហានិភ័យទាំងឡាយ ឬគ្រោះមហន្តរាយធម្មជាតិ និងបរិស្ថានផង ព្រមជាមួយការលើកកំពស់សមត្ថភាពធនធានមនុស្សដើម្បីអាចចៀសផុតពីភាពក្រីក្រដោយខ្លួនឯងនាពេល អនាគត ។ ការសម្រេចឱ្យបាននូវកម្មវត្ថុទាំងនេះ ទាមទារនូវ ១. ពង្រីកបន្ថែម និងធ្វើសុខដុមនីយកម្មលើ អន្តរាគមន៍ការគាំពារសង្គមដែលមានស្រាប់ និង ២. ចាប់អនុវត្តនូវកម្មវិធីថ្មី ដើម្បីគ្របដណ្តប់លើចន្លោះប្រហោងនៃការគាំពារសង្គម។ សេចក្តីប្រកាសរួម រវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ នាពេលបិទ វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ កាលពីថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១០ បានធ្វើការគូសបញ្ជាក់អំពីការគាំទ្រដល់សេចក្តីព្រាងយុទ្ធសាស្រ្តនេះ ហើយបាន ចង្អុលទិសបន្តការអនុវត្តយុទ្ធសាស្រ្ត ដោយធ្វើការសហការឱ្យបានជិតស្និតជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានាតាមរយៈការរៀបចំ ឱ្យមានយន្តការអន្តរកាលដើម្បីធ្វើការសម្របសម្រួលថ្នាក់ជាតិ ដឹកនាំដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យ កសិកម្ម និងជនបទ ។ ផែនការសកម្មភាពមួយចំនួន បានគ្រោង នឹងដាក់ជូនសម័យប្រជុំនេះ ធ្វើការពិភាក្សា និងសម្រេច មុននឹងឈានដល់ការរៀបចំអនុវត្តសកម្មភាពអាទិភាព ក្នុងរយៈ ៦ខែនៃឆ្នាំ២០១០ ផង និងជាទិសដៅ សម្រាប់អនុវត្តនៅដំណាក់កាលទី១ នៃការអនុវត្តយុទ្ធសាស្រ្តនេះរយៈពេលមធ្យម ២០១១-២០១២ ខាង

មុខនេះ ដោយឈរលើមូលដ្ឋានអាទិភាព ដែលមានចែងនៅក្នុងឯកសារ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នភាព ២០០៩-២០១៣ ។

**៥.** មកដល់ពេលនេះ សកម្មភាពមួយចំនួនបានដំណើរការ តែក៏នៅជួបបញ្ហាប្រឈមផងដែរ។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ រួមសហការជាមួយក្រុមការងារអន្តរកាល ដែលមាន តំណាងក្រសួងស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធផ្តើម និងសម្រេចការងារមួយចំនួនមានជាអាទិ៍ :

**៦. ការបង្កើតអង្គភាពដឹកនាំ និងសម្របសម្រួលយុទ្ធសាស្ត្រជាតិស្តីពីការគាំពារសង្គម** - យោងតាមស្មារតីនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នភាព ២០០៩-២០១៣ និងសេចក្តីប្រកាសរួម រវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ នាពេលបិទ វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ កាលពីថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១០ បានធ្វើការគូសបញ្ជាក់ ពីតម្រូវការយន្តការអន្តរកាលដើម្បីធ្វើការសម្របសម្រួល ថ្នាក់ជាតិ ដឹកនាំដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ។ កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១០ ក.ក.ជ. បានចេញសេចក្តីសម្រេច (លេខ២៥៧/កកជ) បង្កើតអង្គភាពដឹកនាំ និងសម្របសម្រួលយុទ្ធសាស្ត្រជាតិស្តីពីការគាំពារសង្គម ដើម្បីផ្តល់ការគាំទ្រគោលនយោបាយ ការត្រួតពិនិត្យ និងវាយតម្លៃ ការគ្រប់គ្រងព័ត៌មាន និងចំណេះដឹង និងការកសាងសមត្ថភាព។ លក្ខខណ្ឌការងារលំអិតនៃអង្គភាពសម្របសម្រួល នឹង ចងក្រងនៅពេលបន្ទាប់ ។

**៧. ដំណើរការអនុម័តយុទ្ធសាស្ត្រគាំពារសង្គម** — សេចក្តីព្រាងចុងក្រោយ និងឯកសារពាក់ព័ន្ធនៃយុទ្ធសាស្ត្រគាំពារសង្គម បានត្រូវបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី កាលពីចុងខែសីហា ២០១០ ដើម្បីស្នើសុំការពិនិត្យនិងអនុម័តពីសម័យពេញអង្គនៃកិច្ចប្រជុំគណៈរដ្ឋមន្ត្រី ។ សម័យប្រជុំក៏រិតបច្ចេកទេស បានរៀបចំឡើងនៅថ្ងៃទី១២-១៣ខែតុលានេះ ដឹកនាំដោយអគ្គលេខាធិការរាជរដ្ឋាភិបាល និងគណៈកម្មាធិការសេដ្ឋកិច្ចសង្គម និងវប្បធម៌ និងក្រុមប្រឹក្សានីតិកម្ម ។ បន្ទាប់មក នឹងមានការប្រជុំអន្តរក្រសួង ដើម្បីពិនិត្យចុងក្រោយមុននឹងដាក់ក្នុងរបៀបវារៈនៃការប្រជុំគណៈរដ្ឋមន្ត្រីនាពេលដ៏ខ្លីខាងមុខនេះ ។

**៨. ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រគាំពារសង្គម** — ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍កសិកម្មនិងជនបទ បានរៀបចំពង្រាងផែនការសកម្មភាពមួយ មុននឹងឈានដល់ការរៀបចំអនុវត្ត សកម្មភាពអាទិភាពក្នុងរយៈ ៦ខែនៃឆ្នាំ២០១០ ផង និង ជាទិសដៅ សម្រាប់អនុវត្តនៅដំណាក់កាលទី១ នៃការអនុវត្តយុទ្ធសាស្ត្រនេះរយៈពេលមធ្យម ២០១១-២០១២ ខាងមុខ នេះ ដោយឈរលើមូលដ្ឋានអាទិភាព ដែលមានចែងនៅក្នុងឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នភាព២០០៩-២០១៣។ សកម្មភាពដែលបានគ្រោងមានការកសាងឡើងនូវសមត្ថភាពស្ថាប័ន នៅក្នុងយន្តការសម្របសម្រួលថ្នាក់កណ្តាល និងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ នឹងជាអាទិភាពចម្បងសម្រាប់អនាគតបន្ទាប់ទៅនេះ គឺជាការរៀបចំស្ថាប័ន និងការសម្របសម្រួលដោយមានតួនាទីជាក់លាក់ ព្រមទាំងរចនាសម្ព័ន្ធត្រួតពិនិត្យសម្រាប់ការបន្ត **យុទ្ធសាស្ត្រគាំពារសង្គម** ក្នុងដំណាក់កាលមធ្យម និងវែង។

**៩. ផែនទីតម្រង់ផ្លូវសម្រាប់អនុវត្តយុទ្ធសាស្ត្រគាំពារសង្គម** —នៅចុងខែកញ្ញានេះ ដោយមានការគាំទ្រហិរញ្ញប្បទានពី ភ្នាក់ងារអូស្ត្រាលីសម្រាប់កិច្ចអភិវឌ្ឍន៍អន្តរជាតិនិងចាត់ចែងដោយធនាគារពិភពលោក ក.ក.ជ. បានដឹកនាំការរៀបចំសិក្ខាសាលា និងសម័យប្រជុំ ជាច្រើន ដើម្បីពិភក្សារៀបចំនូវផែនទីតម្រង់ផ្លូវរួមមួយសម្រាប់ត្រៀមអនុវត្ត កម្មវិធីគាំពារសង្គមដែលកំពុងមានសកម្មភាព និងការសាកល្បងអនុវត្តកម្មភាពសង្គមកិច្ចថ្មីៗ នឹង កាន់តែមានសុខុដុមនីយភាព និងត្រូវពិចារណាវាយតម្លៃធ្វើសមាហរណកម្មទៅក្នុង កម្មវិធីកម្រិតជាតិ កាន់ តែធំជាងមុន ក្នុងការអនុវត្ត **យុទ្ធសាស្ត្រគាំពារសង្គម** ក្នុងដំណាក់កាលមធ្យម និងវែង ដើម្បីនាំយកមកនូវ គម្រោងការផ្សេងៗមួយចំនួនទៀត ឱ្យស្ថិតនៅក្រោមកម្មវិធីដែលមានលក្ខណៈចម្រុះមួយ យ៉ាងហោច ណាស់ ក្នុងរាល់កម្មវត្ថុនីមួយៗ។

### ១. ផែនការសកម្មភាពឆ្នាំ២០១០

១. ត្រូវបន្តពិភក្សាការងារបច្ចេកទេសលំអិតជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ
២. ផ្ដើមការងារវាយតម្លៃសមត្ថភាព និងតម្រូវការពង្រឹងធនធានមនុស្ស
៣. រៀបចំយន្តការតាមដាន និងវាយតម្លៃ និងការងារបណ្ដុះបណ្ដាល
៤. ចាប់ផ្ដើមដំណើរការធ្វើសង្គតិភាព និងសមាហរណកម្មជាមួយដៃគូ
៥. ពិនិត្យលើទម្រង់នៃការស្ទង់តម្រូវការថវិការ

### ២. ផែនការសកម្មភាព ឆ្នាំ២០១១

១. ធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌនៃកម្មវិធី គាំពារសង្គម
២. រៀបចំសិក្ខាសាលាបណ្ដុះបណ្ដាលពង្រឹងធនធានមនុស្ស
៣. រៀបចំពង្រាងតម្រូវការថវិកា
៤. ពង្រឹងនិងពង្រីកការងារទំនាក់ទំនងរវាងអង្គភាពសម្របសម្រួល និងអង្គភាពអនុវត្តសកម្មភាព
៥. រៀបចំកម្មវិធីសាកល្បង
៦. រៀបចំកម្មវិធីដែលមានស្រាប់ ដើម្បីពង្រីកវិសាលភាព
៧. រៀបចំការងារចាប់ផ្ដើម និងការងារតាមដាន និងវាយតម្លៃ
៨. ពង្រាងតម្រូវការថវិកាសម្រាប់កម្មវិធីសាកល្បង និង សកម្មភាពបន្ត
៩. ពង្រឹងសកម្មភាពអាទិភាពមួយចំនួន

### ៣. ផែនការសកម្មភាព ឆ្នាំ២០១២

១. ពង្រឹងសមត្ថភាព និងបណ្ដុះបណ្ដាលអង្គភាពអនុវត្តកម្មវិធីតាមក្រសួង-ស្ថាប័នថ្នាក់ជាតិ និងស្ថាប័នថ្នាក់ក្រោម ជាតិ

២. អនុវត្តកម្មវិធីសាកល្បង

៣. អនុវត្តកម្មវិធីដែលមានស្រាប់

**៤. ផែនការសកម្មភាពចំពោះមុខ**

១. បង្កើតយន្តការ និងរចនាសម្ព័ន្ធតាមដាននិងវាយតម្លៃ នៃអង្គភាពសម្របសម្រួល និងក្រសួងស្ថាប័នពាក់ព័ន្ធ

២. រៀបចំតម្រូវការសិក្ខាសាលាដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ

៣. ចាប់ផ្តើមធ្វើបច្ចុប្បន្នកម្មកម្មវិធីគាំពារសង្គមដែលកំពុងដំណើរការ

៤. ធ្វើការពិនិត្យ និងវាយតម្លៃលើកម្មវិធីធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលជាឧបករណ៍ដ៏សំខាន់សម្រាប់កំណត់ចំណុចគោលដៅ

៥. កំណត់តួនាទី ភារកិច្ចលំអិត នៃអង្គភាពដឹកនាំ និងសម្របសម្រួល

**១០. ការធ្វើតម្រែតម្រង់ និងសុខុដុមនីយកម្ម** - ការអនុវត្តអន្តរាគមន៍គាំពារសង្គម ជាភារកិច្ច និងជាការទទួលខុសត្រូវនៃក្រសួងជំនាញ និងស្ថាប័នអជ្ញាធរមូលដ្ឋានគ្រប់ថ្នាក់ ។ **យុទ្ធសាស្ត្រគាំពារសង្គម** មានគោលបំណងក្នុងការបំពេញបន្ថែមនូវកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងជំនាញ ក្នុងការសម្រេចឱ្យបាននូវគោលដៅតាមវិស័យជំនាញក្នុងវិធានការណ៍គាំពារសង្គម តាមរយៈការផ្តល់នូវក្របខណ្ឌនៃការអនុវត្តប្រកបដោយនិរន្តភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិ។ កម្មវិធីភាគច្រើននៃយុទ្ធសាស្ត្រគាំពារសង្គម មានចរិតជាអន្តរវិស័យ និងទាមទារនូវការសម្របសម្រួលអន្តរក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល ដើម្បីជៀសវាងការត្រួតជាន់គ្នាជាលក្ខណៈវិស័យនិងតំបន់ភូមិសាស្ត្រ ក៏ដូចជាដើម្បីធ្វើសុខុដុមនីយកម្មលើការអនុវត្តនិតិវិធី និងដើម្បីសម្របសម្រួលលើការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាព និងដោយសក្តិសិទ្ធនូវធនធានដែលទទួលបានពីថវិកាជាតិ និងដៃគូអភិវឌ្ឍន៍។ ប្រការនេះ ក៏បាននាំមកតម្រូវការនៃ ការប្រាស្រ័យទាក់ទងដោយសកម្មជាមួយដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ។ រាជរដ្ឋាភិបាល នឹងធានាឱ្យមានប្រសិទ្ធភាពកិច្ចការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិ មានថ្នាក់ខេត្ត-ក្រុង និងស្រុក ខណ្ឌ ។ នៅថ្នាក់ឃុំ-សង្កាត់ ដែលមានគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ និងមានតួនាទីកំណត់ចំណុចគោលដៅ និងកិច្ចការអនុវត្តសកម្មភាពគាំពារសង្គមនៅថ្នាក់មូលដ្ឋាន ។ នៅក្នុងបរិការនេះ ក.ក.ជ. នឹងធ្វើការសម្របសម្រួលជាមួយគ្រប់ក្រសួងស្ថាប័ន និងភាគីដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ដើម្បីសម្រេចឱ្យបាននូវសុខុដុមនីយកម្ម និងសង្គតិភាពនៃគោលនយោបាយ និងកម្មវិធីនានារយៈពេល៥ឆ្នាំ និងទៅមុខ ។

**១១. នៅក្នុងឱកាសធ្វើមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៦៥**នៅទីក្រុងញូវយ៉ក កាលពីថ្ងៃ ២០ ដល់ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ ប្រមុខរដ្ឋ និងថ្នាក់ដឹកនាំប្រទេសជាសមាជិក បានបញ្ជាក់នូវគោល ជំហរសហការរួមគ្នាដើម្បីជំរុញលើកកំពស់ការរីកចំរើន និងជឿនលឿនក្នុងវិស័យសេដ្ឋកិច្ច និងសង្គម ដល់គ្រប់ពលរដ្ឋទាំងមូល ។ មហាសន្និបាតបានចេញសេចក្តីសម្រេចរួមមួយ ដែលបានកំណត់សកម្មភាព ជាអាទិភាព

ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សនៅឆ្នាំ២០១៥ដែលមានចំណងជើង: "រក្សាពាក្យសន្យា—**រួមគ្នាដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្ស**" ។ ក្នុងចំណោមអាទិភាពជាច្រើន ខ្ញុំសូមលើក តែចំណុច៣ មកជូនអង្គប្រជុំដើម្បីធ្វើការពិចារណា និង សហការនៅកម្ពុជា។ សេចក្តីសម្រេចរួមនោះ បាន កំណត់ថាជាអាទិ៍ *"រដ្ឋនីមួយៗត្រូវលើកកំពស់ និងពង្រឹងភាពជាម្ចាស់និងជាអ្នកដឹកនាំឈានមុខ ក្នុងកិច្ចការអភិវឌ្ឍន៍ដែលជាគន្លិះឱ្យសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្ស(វាក្យខណ្ឌ៣៦)*"។ វាក្យខណ្ឌ ៤១នៃសេចក្តីសម្រេចរួមនោះ ទាមទារ *"ឱ្យបង្កើនសង្គតិភាពនៃគោលនយោបាយសម្រាប់ការអភិវឌ្ឍន៍ពី គ្រប់ភាគីទាំងអស់*" និងវាក្យខណ្ឌ៥១ ចែង" *ពីការចាំបាច់ពីធានាផ្តល់សេវាគាំពារសង្គមឱ្យបានជាសាកល ដែលជាកត្តាកំណត់ក្នុងការចូលរួមចំណែកដ៏សំខាន់ ក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍នានាបន្ថែមទៀត* "។

**១២. យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ** បានរៀបចំតាក់តែងឡើង នៅក្នុងក្របខណ្ឌនៃការបង្កើនល្បឿនឱ្យសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សនៅកម្ពុជា តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ដែលនេះ គឺជាការប្តេជ្ញាចិត្តយ៉ាងមោះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា និងដោយមានការគាំទ្រពីគ្រប់ដៃគូអភិវឌ្ឍន៍ ដើម្បីសម្រេចបានកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ប្រកបដោយចិរភាពទាំងអស់គ្នា ។

**១៣.** ដើម្បីជំរុញទិសដៅនេះ ឱ្យមានដំណើរការទៅមុខតាមការគ្រងទុកនៃរបៀបវារៈ នៃការគាំពារសង្គមរាជរដ្ឋាភិបាល មានភារកិច្ច និងវិធានការសមស្របដើម្បីធានាឱ្យមានប្រសិទ្ធភាពនៃការប្រើប្រាស់គ្រប់ការគាំទ្រពីដៃគូអភិវឌ្ឍន៍ ។ របៀបគ្រប់គ្រងហិរញ្ញប្បទាន និងជំនួយបច្ចេកទេស រួមគ្នា អាចជាវិធីសាស្ត្រមួយមានប្រសិទ្ធភាព ក្នុងកម្មវិធីពង្រឹងសមត្ថភាពធនធានមនុស្សនិងស្ថាប័ន ។ ដោយឡែកការងារពាក់ព័ន្ធ ការរៀបចំ កម្មវិធី ឬគម្រោង និងកិច្ចការជំនាញពិសេសៗ ដែលមានលក្ខណៈបច្ចេកទេសតម្រូវឱ្យមានការចាត់ចែងតាមជំនាញ ឧត្តមភាព និងយន្តការគ្រប់គ្រងបច្ចេកទេស និងហិរញ្ញវត្ថុ ពិសេសតាមវិស័យ និមួយៗ ។ អាស្រ័យហេតុនេះទាមទារឱ្យមានការពិគ្រោះពិភក្សា ផ្លាស់ប្តូរយោបល់ឱ្យបានទូលំទូលាយជា ប្រចាំជាមួយសមាសភាពគ្រប់ដៃគូអភិវឌ្ឍន៍ ក្នុងក្របខណ្ឌនៃយន្តការពិគ្រោះយោបល់នានា ។ ទស្សនទាន ថ្មីៗជាអាទិ៍ អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ឬតាមវិស័យ ក្នុងការគ្រប់គ្រងចាត់ចែងប្រើប្រាស់ហិរញ្ញប្បទានឱ្យមានប្រសិទ្ធភាពគួរត្រូវយកមកពិចារណា ដើម្បីធានាឱ្យមានសង្គតិភាព និងសុខដុមនីយកម្ម នៃគោលនយោបាយ និងការអនុវត្តយុទ្ធសាស្ត្រគាំពារសង្គមនេះ។

**១៤.** យើងខ្ញុំអរគុណចំពោះការគាំទ្រ និងសហការ ពីគ្រប់ភាគីដៃគូទាំងអស់កន្លងមក និងសុំឱ្យបន្ថែមការគាំទ្រហិរញ្ញប្បទាន និងបច្ចេកទេស និងរួមសហការបន្តទៀតនាពេលអនុវត្តខាងមុខនេះ ។

សូមអរគុណ